ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៨៣៣៨ សហវ.អធស

ថ្ងៃ ... ខែ ... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៩

**ជម្រាបជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**កម្មវត្ថុ** : ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យាស្តីពីការងារស្ថាបនាផ្លូវខេត្តដោយក្រាលកៅស៊ូ DBST ប្រវែង ២ ៧០០ម ទទឹង ៦ម និងចិញ្ចើមក្រាលល្បាយថ្មភ្នំ ទទឹង ១ម សងខាង លើកំណាត់ផ្លូវខេត្តចាប់បំបែកពីផ្លូវជាតិលេខ៥៧ ត្រង់គ.ម១២+៥០០ ក្នុងភូមិកំប៉ូវ ឃុំភ្នំសំពៅ ឆ្ពោះទៅកាន់ផ្លូវលេខ១៥៤ ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង។

**យោង** : -លិខិតលេខ១២៧៩៦ សហវ.អថ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-កំណត់ហេតុចរចាថ្លៃថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ របស់ គ.ល ក្រសួងសាធារណការ និងដឹកជញ្ជូន
-លិខិតលេខ២២៨៦ សក.អលុ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រគល់កិច្ចសន្យាជូននាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ ដើម្បីធ្វើការងារស្ថាបនាផ្លូវខេត្តដោយក្រាលកៅស៊ូ DBST ប្រវែង ២ ៧០០ម ទទឹង ៦ម និងចិញ្ចើមក្រាលល្បាយថ្មភ្នំ ទទឹង ១ម សងខាង លើកំណាត់ផ្លូវខេត្តចាប់បំបែកពីផ្លូវជាតិលេខ៥៧ ត្រង់គ.ម១២+៥០០ ក្នុងភូមិកំប៉ូវ ឃុំភ្នំសំពៅ ឆ្ពោះទៅកាន់ផ្លូវលេខ១៥៤ ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង ក្នុងតម្លៃសរុបចំនួន ៩៥៩.០០០.០០០រៀល (ប្រាំបួនរយហាសិបប្រាំបួនលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការផ្ទេរបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបាន ត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្ត ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាប និងមានវិធានការអនុវត្តបន្តឱ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ។

សូមឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលនូវគារវកិច្ចពីខ្ញុំ។

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- សាលាខេត្តបាត់ដំបង
- នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ
- នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
- មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តបាត់ដំបង
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តបាត់ដំបង
- ឯកសារ-កាលប្បវត្តិ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
រដ្ឋលេខាធិការ

**ជូ ទិវិត្ត**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798